# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១០

(០១/០៤/២០១០-៣០/០៤/២០១០)

យោងតាមផែនការជាតិឆ្នាំ២០១០ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងទិសដៅការងារត្រួតពិនិត្យគ្រឿងញៀនខែមីនា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបង្កើនកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជន ពង្រឹងនូវកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន សំដៅចូលរួមចំណែកទប់ស្កាត់បទល្មើសក្នុងឱកាសចូលឆ្នាំប្រពៃណីជាតិខ្មែរទទួលបានលទ្ធផលល្អប្រសើរ ។

## I/ សភាពការណ៍គ្រឿងញៀននៅកម្ពុជា :

ខែមេសាឆ្នាំ២០១០ មន្ទីរប្រឆាំងគ្រឿងញៀន ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តស្វាយរៀង ខេត្តរតនគិរី ខេត្តកណ្តាល ខេត្តតាកែវ ខេត្តព្រះសីហនុ ខេត្តកំពត ខេត្តពោធិសាត់ និងខេត្តបន្ទាយមានជ័យ បានធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀន ដើម្បីចូលរួមចំណែករក្សានូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ កត់សំគាល់បណ្តាករណីដែលបានធ្វើការបង្ក្រាបភាគច្រើនជាករណីចរាចរជួញដូរចែកចាយនូវប្រភេទ មេតំហ្វេតាមីនគ្រាប់ និង មេតំហ្វេតាមីនទឹកកក(**ICE**) ដែលមានប្រភពនាំមកពីតំបន់ព្រំដែនភាគឥសានចូលមកក្នុងប្រទេស ដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ និងនាំទៅកាន់តំបន់ព្រំដែនភាគពាយ័ព្យប្រទេស ជាក់ស្តែង ស្នងការដ្ឋាននគរបាល ខេត្តបាត់ដំបង បង្ក្រាបបាន១ករណីនិងចាប់យកមេតំហ្វេតាមីន(**WY**)ជិត ២០.០០០ គ្រាប់ ។

ដោយឡែក ខេត្តពោធិសាត់បានបន្តរកឃើញកន្លែងស្តុកប្រេងម្រះព្រៅភ្នំ១កន្លែង ស្ថិតនៅក្នុងឃុំអន្លង់រាប ស្រុកវាលវែង ដែលជាសញ្ញាបង្ហាញថា តំបន់នោះនៅតែមានការផលិតប្រេងម្រះព្រៅភ្នំនៅឡើយ ។

## II / លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន :

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់ចង្អុលដឹកនាំ ណែនាំ លើគ្រប់វិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាអាទិ៍ :

-ការជំរុញឱ្យក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តឱ្យអនុវត្តនូវអនុសាសន៍ដ៏មានតម្លៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

-ការជំរុញការរៀបចំសេវាសុខភាពសំរាប់អ្នកញៀនគ្រឿងញៀន នៅតាមមណ្ឌលបណ្ដោះអាសន្នអប់រំបន្សាប ព្យាបាល គ្រឿងញៀន និងការជំរុញឱ្យមានកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយឱសថមេតាដូន ។

-ការអនុវត្តន៍ផែនការប្រតិបត្តិគំរូ សំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ដើម្បីធ្វើជាចំណុចដកពិសោធន៍សំរាប់ពង្រីកកិច្ចប្រតិបត្តិការឱ្យមានប្រសិទ្ធភាពទៅកាន់រាជធានី-ខេត្តនានា ទូទាំងប្រទេសនៅក្នុងឆមាសទី២ឆ្នាំ ២០១០នេះ ព្រមទាំងការស្វែងរកការគាំទ្រពីសហរដ្ឋអាមេរិកដើម្បីធានានិរន្តរភាពមន្ទីរពិសោធន៍គ្រឿងញៀន ។

### *១-ការកាត់បន្ថយតម្រូវការគ្រឿងញៀន :*

អាជ្ញាធរជាតិ បានរៀបចំកម្មវិធីសំណេះសំណាលមួយនៅខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សំដៅលើកកំពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន ដល់សាស្ត្រាចារ្យ នាយក នាយិកា បុគ្គលិក លោកគ្រូ អ្នកគ្រូ សិស្ស និសិត្ស នៅសាលប្រជុំសាកលវិទ្យាល័យមានជ័យ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០ ។

អគ្គលេខាធិការដ្ឋាន អជបគញ តាមសំណើរបស់សមាគមយុវជនខ្មែរ និងតាមកម្មវិធីដែលផ្តល់ដោយទូរទស្សន៍ ស៊ីធីអិន និង ទូរទស្សន៍កម្ពុជា(ទទក) បានផ្តល់បទសម្ភាសន៍ ក្រោមប្រធានបទស្តីពីយុទ្ធសាស្ត្រជាតិក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន និង គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក៏បានធ្វើការជ្រើសរើសផលិតកម្មភាពយន្ត-វីដេអូ និង ក្រុមហ៊ុននាំចូល-នាំចេញខ្សែភាពយន្ត ចំនួន ១៤ គឺ រស្មីរៃមាស អឹមអិនធើធេនមេន ប៊ីកមេន រស្មីហង្សមាស បុប្ផា កណ្តឹងមាស ពន្លឺនាគហោះ រ៉ក់ប្រូដាក់សិន ហ្វ៊ូរយូ អេហ្វសេអន្តរជាតិ, សាន់ដេវីដេអូ, ចម្រៀងអ្នក, រស្មីពានមាស និង តារាវីដេអូកម្ពុជា និងអង្គការចំនួន ៣ គឺ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា អង្គការឆេមស៍ និង អង្គការសុខភាពគ្រួសារអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការងារផ្សព្វផ្សាយដើម្បីទប់ស្កាត់ការជួញដូរនិងការប្រើប្រាស់គ្រឿងញៀន ។

ដោយឡែក បណ្តាខេត្ត និង សមាគមមួយចំនួន ក៏បានបន្តការយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន សរុបបានចំនួន ១៩.១៩១ នាក់ ក្នុងនោះរួមមាន ÷

| **អង្គភាព** | **ខ្លឹមសារ** | **សមាសភាព** | **ចំនួន** |
|---|---|---|---|
| ខេត្តបាត់ដំបង(១៤លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | ប្រជាពលរដ្ឋ | ៣.៨៨៤ នាក់ |

| | | | |
|---|---|---|---|
| ខេត្តពោធិសាត់ (១លើក) | ផែនការបង្ក្រាបការជួញដូរ ប្រើប្រាស់ | អធិការរងទទួលបន្ទុកយុត្តិធម ក្រុង ស្រុក និង ប៉ុស្តិ៍នគរបាលរដ្ឋបាល | ៥៥ នាក់ |
| សមាគមនារីខេត្តប៉ៃលិន | គ្រោះថ្នាក់នៃគ្រឿងញៀន | ស្ត្រីបំរើកំសាន្ត | ៣៤២ នាក់ |
| ខេត្តកំពង់ធំ (៤លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | ក្រុមហ៊ុន និង ប្រជាជន | ៨៤៥ នាក់ |
| ខេត្តកំពត (៨លើក) | គ្រោះថ្នាក់នៃគ្រឿងញៀន | លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស (៨វិទ្យាល័យ-២៨អនុវិទ្យាល័យ) | ១៣.៩៥៥ នាក់ |
| ខេត្តមណ្ឌលគីរី | គ្រោះថ្នាក់នៃគ្រឿងញៀន | ម្ចាស់ខារ៉ាអូខេ និង ស្ត្រីខារ៉ាអូខេ | ២៦ នាក់ |
| ខេត្តឧត្តរមានជ័យ | គ្រោះថ្នាក់នៃគ្រឿងញៀន | ក្រុមប្រឹក្សាឃុំ និង ប្រជាពលរដ្ឋ | ៥១ នាក់ |
| បណ្តាញសមាគមយុវជនខ្មែរ | គ្រោះថ្នាក់នៃគ្រឿងញៀន | ស្ត្រីបំរើសេវាកំសាន្ត និង ទីសាធារណៈ | ៣៣ នាក់ |
| សរុប | | | ១៩.១៩១ នាក់ |

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន :

ខែមេសានេះ បង្ក្រាបបទល្មើសបាន **៣៥ ករណី** ឃាត់ខ្លួនជនល្មើសចំនួន **៦៣** នាក់(ប្រុស ៥១នាក់, ស្រី ១២នាក់) បញ្ជូនទៅតុលាការ ក្នុងនោះមាន : ជនជាតិខ្មែរ **៥៨** នាក់ (ប្រុស **៤៧** នាក់ ស្រី **១១** នាក់), វៀតណាម **៣** នាក់ (ប្រុស **២** នាក់ ស្រី **១** នាក់) ឡាវ **២** នាក់(ប្រុស) ។

**វត្ថុតាងចាប់យក** មេតំហ្វេតាមីន **WY ២០.៩០៨** គ្រាប់, ម្សៅមេតំហ្វេតាមីន **ICE ៩៤,៨៧** ក្រាម, ម្សៅពណិ ផ្កាឈូក **៥៤៥** ក្រាម, កញ្ឆាក្រៀម **២៥០** ក្រាម, លុយដុល្លារក្លែងក្លាយក្រដាស់**២០**ចំនួន **២៣៧** សន្លឹក និងក្រដាស**១០០** ចំនួន**១**សន្លឹក, ជញ្ជីង **១**, រថយន្ត **២**គ្រឿង, ម៉ូតូ**៨**គ្រឿង, ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់គ្រឿងញៀនមួយចំនួន ។

### អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើស រួមមាន :

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ចរាចរជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៦** | **១១** | **០** | ៦ | ១១ | 0 | | | | | | |
| ២ | រាជធានីភ្នំពេញ | **៨** | **១៨** | **៤** | ៦ | ៨ | ២ | ២ | ១០ | ២ | | | |
| ៣ | កណ្តាល | **២** | **៦** | **៣** | ២ | ៦ | ៣ | | | | | | |
| ៤ | តាកែវ | **០** | **១** | **០** | | | | | | | 0 | ១ | 0 |
| ៥ | ព្រះសីហនុ | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៦ | សៀមរាប | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៧ | ស្វាយរៀង | **២** | **៣** | **១** | ២ | ៣ | ១ | | | | | | |
| ៨ | រតនគីរី | **១** | **១** | **០** | ១ | ១ | 0 | | | | | | |
| ៩ | កំពត | **១** | **០** | **០** | ១ | 0 | 0 | | | | | | |
| ១០ | បាត់ដំបង | **៧** | **១២** | **២** | ៣ | ៤ | 0 | ៤ | ៨ | ២ | | | |
| ១១ | បន្ទាយមានជ័យ | **៣** | **៥** | **០** | ៣ | ៥ | 0 | | | | | | |
| ១២ | ពោធិសាត់ | **១** | **២** | **០** | ១ | ១ | 0 | | | | 0 | ១ | 0 |
| ១៣ | ប៉ៃលិន | **២** | **២** | **២** | | | | ២ | ២ | ២ | | | |
| **សរុប** | | **៣៥** | **៦៣** | **១២** | **២៧** | ៤១ | ៦ | **៨** | ២0 | ៦ | **០** | ២ | |

អគ្គលេខាធិការដ្ឋាន អជបគញ បានសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ធ្វើការប្រមូលទិន្នន័យសារធាតុ

គីមីផ្សំ ដែលមានអាជ្ញាប័ណ្ណនាំចូលប្រចាំខែមេសាឆ្នាំ២០១០ សរុបមានចំនួន **2.372.500 Kgs** ក្នុងនោះមាន :

| ឈ្មោះ សារធាតុគីមី | ក្រសួង សុខាភិបាល | | ក្រសួង ឧស្សាហកម្ម | | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សរុប | |
|---|---|---|---|---|---|---|---|---|
| | Kg | L | Kg | L | Kg | L | Kg | L |
| Soda Ash | | | | | 600.000 | | **600.000** | |
| Toluene | | | | | 72.250 | | **72.250** | |
| Methylene Chloride | | | | | 85.150 | | **85.150** | |
| Methyl Ethyl Ketone | | | | | 34.200 | | **34.200** | |
| Acetone | | | | | 5.000 | | **5.000** | |
| Ethyl Acetate | | | | | 10.000 | | **10.000** | |
| Caustic Soda | | | | | 120.000 | | **120.000** | |
| Formic Acid | | | | | 13.000 | | **13.000** | |
| Glacial Acetic Acid | | | | | 57.500 | | **57.500** | |
| Sodium Carbonate | | | | | 376.000 | | **376.000** | |
| Sodium Hydroxyde | | | | | 40.250 | | **40.250** | |
| Sodium Sulfate | | | | | 952.000 | | **952.000** | |
| Sodium Bicarbonate | | | | | 6.000 | | **6.000** | |
| Thinner | | | 350 | | | | **350** | |
| **Total :** | | | **350** | | **2.372.150** | | **2.372.500** | |

ដោយឡែក កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំអន្លង់រាប បានសហការជាមួយកម្លាំងកងរាជអាវុធហត្ថស្រុកវាលវែង ដឹកនាំដោយព្រះរាជអាជ្ញាអមសាលាដំបូងខេត្តពោធិសាត់ ចុះចាប់ប្រេងម្រះព្រៅភ្នំបានចំនួន ៥០ ប៊ីដុង ស្មើនឹង ២.00៥ លីត្រ នៅភូមិក្រាំងឆ្កៀង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិសាត់ នាថ្ងៃទី២៤ខែមីនាឆ្នាំ ២០១០ ដែលបច្ចុប្បន្នសមត្ថកិច្ចចំរុះបានប្រគល់ឱ្យកងរាជអាវុធហត្ថស្រុកវាលវែងរក្សាទុក ។

### ៣-ការព្យាបាលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន :

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក្នុងឱកាសជួបពិភាក្សាការងារជាមួយលោកជំទាវ ការ៉ូល រ៉ុដលី ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក បានសំដែងនូវជំហរជាក់លាក់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងការបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា ពិសេសជាមួយ**UNODC** ដើម្បីអនុវត្តកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ដោយចាត់ទុកកម្មវិធីនេះជាយុទ្ធសាស្ត្រចំបងក្នុងការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រឿងញៀន ។ ដោយឡែកជាមួយអង្គការ ខាន់ណា ដែលគាំទ្រថវិកាដោយសហរដ្ឋអាមេរិក អាជ្ញាធរជាតិនឹងបន្តដំណើរការកម្មវិធីព្យាបាលអ្នកញៀន

នៅតាមសហគមន៍ ដែលតាមការគ្រោង គំរោងនេះនឹងអនុវត្តកម្មវិធីដើម្បីគាំទ្រដល់មណ្ឌលសុខភាពនៅក្នុងឃុំ/សង្កាត់អា-ទិភាពប្រហែលជា៤០០ ។ លោកជំទាវឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបានគាំទ្រទាំងស្រុងនូវគំនិតផ្តួចផ្តើមនេះ ។

ក្រៅពីនេះ អគ្គលេខាធិការដ្ឋាន អជបគញ ក៏បានរៀបចំបែបបទបញ្ជូនសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនទៅទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ ព្រមទាំងបានបន្តកិច្ចសហការជាមួយខេត្តព្រះសីហនុ, **ក្រុមហ៊ុនម៉ុងរិទ្ធីគ្រុប,** ក្នុងការធ្វើកម្មសិទ្ធដីដែលក្រុមហ៊ុនម៉ុងរិទ្ធីគ្រុប បានប្រគល់ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

បានចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការត្រួតពិនិត្យឡើងវិញលើការអនុវត្តន៍ផែនការយុទ្ធសាស្រ្តជាតិ លើកទី២ និងការការត្រៀមលក្ខណៈរៀបចំផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយនិងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍និងជម្ងឺអេដស៍ លើកទី៣ (២០១១-២០១៥) ។

## ***៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ :***

អនុវត្តតាមអនុសាសន៍ដ៏មានតម្លៃរបស់សម្តេចអគ្គមហាសេនាបីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជួបពិភាក្សាការងារជាមួយលោកជំទាវ ការ៉ូល រ៉ុដលី(**CarolRodley**) ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ដែលនៅក្នុងជំនួបពិភាក្សានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានលើកឡើងពីបញ្ហាប្រឈមក្នុងការធានានិរន្តរភាពមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ជាតិ ដោយសារកន្លងមកមន្ទីរពិសោធន៍នេះត្រូវបានគាំទ្រដោយគំរោងរបស់អង្គការ**JICA** ហើយបច្ចុប្បន្នគំរោងនេះបានបញ្ចប់ពីខែមីនាឆ្នាំ២០១០ ។ ជាមួយនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានស្នើសុំឱ្យអាមេរិកជួយបង្កើតមន្ទីរពិសោធន៍គ្រឿងញៀននៅថ្នាក់តំបន់ចំនួន ២ កន្លែងបន្ថែមទៀត ដែលលោកជំទាវបានទទួលយកសំណើនេះទៅពិចារណា និងស្នើសុំឱ្យភាគីកម្ពុជាលើកគំរោងលំអិតពីតម្រូវការជាក់ស្តែងនូវឧបករណ៍សម្ភារៈមន្ទីរពិសោធន៍ ព្រមទាំងការងារបណ្តុះបណ្តាលជំនាញ ។

ក្រៅពីនេះ អាជ្ញាធរជាតិបានចាត់មន្ត្រីចំនួន១២រូប រួមមាន មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន(BLO) នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ចំនួន៩រូប និងមន្ត្រីអគ្គលេខាធិការដ្ឋាន ចំនួន៣រូប ទៅចូលរួមក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយការិយាល័យអចិន្ត្រៃយ៍គ្រឿងញៀននិងឧក្រិដ្ឋកម្មវៀតណាម នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែននៃប្រទេសទាំងពីរឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត ។ ក្រៅពីការប្រជុំផ្លាស់ប្តូរបទពិសោធន៏បំពេញឱ្យគ្នាទៅវិញទៅមក ភាគីវៀតណាមបានសន្យា :

-ជួយបង្កើតការិយាល័យទំនាក់ទំនងព្រំដែនចំនួន ២ កន្លែងដល់កម្ពុជា ស្ថិតនៅច្រកទ្វារអន្តរជាតិភ្នំដិន ខេត្តតាកែវ និង ច្រកត្រពាំងផ្លុង ខេត្តកំពង់ចាម ។

-ជួយធ្វើប៉ាណូផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀនដល់កម្ពុជា ចំនួន២កន្លែង នៅច្រកទ្វារអន្តរជាតិបាវិតខេត្តស្វាយរៀង និងច្រកទ្វារអន្តរជាតិត្រពាំងផ្លុង ខេត្តកំពង់ចាម ។

-ភាគីវៀតណាមបានជូនដំណឹងថា បានធ្វើការសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងក្រសួងការបរទេសវៀតណាម អំពីបញ្ហាថវិកាដែលត្រូវជួយកម្ពុជាក្នុងការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាល ស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន គឺរងចាំតែសភាអនុម័តប៉ុណ្ណោះ ហើយនៅក្នុងពេលឆាប់ៗនេះប្រតិភូវៀតណាមមួយក្រុមនឹងមកកម្ពុជា ដើម្បីពិនិត្យមើលស្ថានភាពភូមិសាស្ត្រដែលត្រូវសាងសង់មជ្ឈមណ្ឌល ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានរៀបចំបែបបទស្នើសុំសិទ្ធប្រទានពីសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខាលើឯកសារគំរោងរបស់ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការគ្រឿងញៀននិងបទឧក្រិដ្ឋ(UNODC) ស្តីពីការពង្រឹងការងារស៊ើបអង្កេត ស្រាវជ្រាវ និងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន ដើម្បីបានដាក់ឱ្យអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅពង្រឹងការងារត្រួតពិនិត្យគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។

ដោយឡែក អគ្គលេខាធិការ អជបគញ បានជួបប្រជុំជាមួយគណៈប្រតិភូអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ ដើម្បីពិភាក្សាលើការអនុវត្តន៍គំរោងដែលគាំទ្រដោយអគ្គរដ្ឋអាជ្ញានៃសាធារណរដ្ឋកូរ៉េ លើកទី២ ។ ភាគីកូរ៉េបានពិភាក្សារួមគ្នាជាមួយកម្ពុជា ដោយបានពិនិត្យយ៉ាងល្អិតល្អន់នូវចំណុចអាទិភាពមួយចំនួន ស្របទៅនឹងសភាពការណ៍គ្រឿងញៀននៅកម្ពុជា ជាអាទិ៍ ការងារផ្សព្វផ្សាយអប់រំ ដោយផ្តោតសំខាន់ទៅលើគោលដៅក្រុង ខណ្ឌ ស្រុក នៅតាមព្រំដែនដែលមានមុខសញ្ញារងគ្រោះ, ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ដោយផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលសមត្ថភាពជំនាញដល់មន្ត្រីអនុវត្តន៍ច្បាប់, ការគ្រប់គ្រងនិងការត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀន, ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្តោតទៅលើការបង្កើតមជ្ឈមណ្ឌលជាតិ ការពង្រឹងមណ្ឌលបណ្តោះអាសន្នដែលមានស្រាប់ ការរៀបចំបទដ្ឋានព្យាបាលទៅតាមនិយាមវេជ្ជសាស្ត្រ, ការពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ ។

***៥-នីតិកម្ម :***

តាមរបាយការណ៍របស់ក្រសួងយុត្តិធមិ ពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសារសេចក្តីព្រាងច្បាប់នេះមានច្រើនមាត្រា និងមានលក្ខណៈស្មុគស្មាញលើទិដ្ឋភាពបច្ចេកទេស ហើយត្រូវរៀបចំឡើងវិញលើរចនាសម្ព័ន្ធនិងទម្រង់ ជាពិសេស ការរៀបចំលំដាប់មាត្រា និងវាយអត្ថបទឡើងវិញជាអក្សរ យូនីកូដ ដូច្នេះក្រុមការងារត្រូវការពេលវេលាដើម្បីផ្ទៀងផ្ទាត់ឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដែលអាចចប់សព្វគ្រប់នៅចុងខែឧសភានេះ ។

## III/ ការសន្និដ្ឋាន :

ក្នុងខែមេសានេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានបន្តយកចិត្តទុកដាក់អនុវត្តតាមអនុសាសន៍ដ៏មានតម្លៃរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងផែនការជាតិឆ្នាំ២០១០ ទទួលបានលទ្ធផលល្អប្រសើរ ។

ដោយមានការចូលរួមពីសំណាក់ក្រសួង-ស្ថាប័ន គណៈកម្មាធិការ ត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន យើងបានបន្តយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និង បង្ការទប់ស្កាត់ការប្រើបំពានគ្រឿងញៀនយ៉ាងផុលផុស ។ ប៉ុន្តែការងារនេះ យើងបានពិនិត្យឃើញពីចំណុចខ្វះខាតមួយចំនួនរបស់រដ្ឋអំណាចនៅមូលដ្ឋាន ដែលពុំទាន់បានអនុវត្តការផ្សព្វផ្សាយអប់រំនេះឱ្យបានស៊ីជម្រៅនៅតាមគោលដៅផ្ទះសំណាក់ សណ្ឋាគារ កន្លែងសប្បាយនានា ជាពិសេស ការធ្វើកិច្ចសន្យារដ្ឋបាលជាមួយម្ចាស់មូលដ្ឋានអាជីវកម្មទាំងនោះនៅមិនទាន់ទទួលបានប្រសិទ្ធភាពខ្ពស់ ។

អង្គភាពអនុវត្តច្បាប់គ្រប់ប្រភេទ បានបន្តយកចិត្តទុកដាក់បង្ក្រាបបានបទល្មើសធំៗ និង បទល្មើស ចែកចាយតូចៗជាច្រើន និងបានអនុវត្តវិធានការស្រាវជ្រាវជាមូលដ្ឋាន ដើម្បីប្រមូលផ្តុំភ្ជាប់មុខសញ្ញាល្មើស ក្រុមក្មេងទំនើង ក្តាប់សភាពការណ៍ និងទប់ស្កាត់បានមុនសកម្មភាពល្មើសកើតឡើង សំដៅចូលរួមចំណែករក្សាសន្តិសុខ សណ្តាប់ ធ្នាប់សង្គម នាឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ ។ ប៉ុន្តែយើងនៅមិនទាន់វាយចំក្រុមមេខ្លោងនិងជនដែលនៅពីក្រោយខ្នង ជាពិសេស នៅមិនទាន់បង្ក្រាបឱ្យបានស្មើដៃគ្នា ក្នុងពេលតែមួយជាមួយគ្នា ឱ្យដូចភ្លៀងរលឹមកុំឱ្យជនល្មើសលាក់ខ្លួនបាន តាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី នៅក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ។

## IV/ ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១០ :

### *១. ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន :*

-បន្តកិច្ចសហការនិងសំរបសំរួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តន៍អនុសាសន៍ណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី នាថ្ងៃទី១៧ខែមីនាឆ្នាំ២០១០ ក្នុងនោះរួមមាន ការសរសេរសារអប់រំពីគ្រឿងញៀនបិទលើផលិតផលក្នុងស្រុក, ការសរសេរសារអប់រំគ្រឿងញៀនចាក់ផ្សាយតាមស្ថានីយ៍វិទ្យុ-ទូរទស្សន៍រដ្ឋនិងឯកជន សារព័ត៌មាន, ការបំផុសឱ្យ សិល្បករ សិល្បការិនី ពិធីករ ពិធីការិនី បន្តនិងបង្កើនការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន, ការជំរុញឱ្យក្រុមហ៊ុនផលិតខ្សែភាពយន្ត ខារ៉ាអូខេ ចម្រៀងកាយវិការ សរសេរសារអប់រំពីគ្រឿងញៀន ដាក់នៅក្បាល **Casette** វីដេអូ មុននឹងចេញទិដ្ឋាការឱ្យចាក់ផ្សាយ ជាដើម ។ល។

-បន្តសហការជាមួយស្ថានីយ៍ ទូរទស្សន៍ រដ្ឋនិងឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូមួយចំនួន ក្នុងការផ្តល់នូវបទសម្ភាសន៍ស្តីពីបញ្ហាគ្រឿងញៀននៅកម្ពុជា និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

### *២. ការងារព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម និង ការកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀន*

-ត្រៀមលក្ខណៈជូនឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជួបពិភាក្សាការងារជាមួយក្រុមការងាររបស់អង្គការសហប្រជាជាតិ (ការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម, អង្គការសុខភាពពិភពលោក, អង្គការអេដស៍សហប្រជាជាតិ, មូលនិធិសហប្រជាជាតិ

សំរាប់កុមារ អំពីការរៀបចំសេវាព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ( ថ្ងៃទី០៦/៥/២០១០) ។

-បន្តជំរុញការរៀបចំធ្វើកម្មសិទ្ធដី ដែលក្រុមហ៊ុនម៉ុងរិទ្ធីគ្រួបបានប្រគល់ឱ្យអាជ្ញាធរជាតិ និងបន្តកិច្ចដំណើរការឈូសឆាយដី ដើម្បីសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងការរៀបចំសេចក្តីព្រាងស្តីពីតំរូវការអប្បបរមាក្នុងការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

-បន្តជំរុញការតម្លើងបញ្ជីឈ្មោះ ឃុំ សង្កាត់អាទិភាព សំរាប់ធ្វើសកម្មភាពត្រួតពិនិត្យគ្រឿងញៀននៅឆ្នាំ២០១០, ឈ្មោះនិងទីតាំងមណ្ឌលសុខភាព, ឈ្មោះទីតាំងនិងវិសាលភាពនៃការអនុវត្តន៍ការងាររបស់អង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀន និងជម្ងឺអេដស៍នៅរាជធានី-ខេត្ត ។

-បន្តកិច្ចសហការជាមួយក្រុមតំណាងអង្គការសហប្រជាជាតិ(UN) ក្រសួង-ស្ថាប័ន អង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីសម្របសម្រួលធ្វើឱ្យគំរោងស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍នៅក្នុងប្រទេសកម្ពុជា អាចចាប់ដំណើរការអនុវត្តបានឆាប់រហ័ស ។

## ៣-ការពង្រឹងសមត្ថភាពអនុវត្តច្បាប់

-បន្តកិច្ចសហការ និង សម្របសម្រួលជាមួយភាគីអូស្ត្រាលី ដើម្បីផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីអនុវត្តន៍កម្ពុជា ពីជំនាញព័ត៌មានចារកម្ម ។

-បន្តកិច្ចសហការនិងសម្របសម្រួលជាមួយសហរដ្ឋអាមេរិក ក្នុងការស្នើសុំឱ្យជួយដល់ការធានានិរន្តរភាពមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់ជាតិ និងការស្នើសុំមន្ទីរពិសោធន៍គ្រឿងញៀនថ្នាក់តំបន់ចំនួន២បន្ថែមទៀត ។

## ៤-កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមចូលរួមក្នុងសន្និសីទស្តីពីការអនុវត្តន៍ច្បាប់គ្រឿងញៀនអន្តរជាតិ លើកទី២៧(IDEC) នៅប្រទេសប្រេស៊ីលពីថ្ងៃទី២៤ ខែមេសា ដល់ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១០ ។

-ត្រៀមទៅចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ នៃប្រទេសហត្ថលេខីលើអនុស្សារណៈយោគយល់គ្នា(MOU)ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងដាណាង ប្រទេសវៀតណាម ( ថ្ងៃទី១០-១៥ ខែឧសភា ឆ្នាំ២០១០) ។

-ត្រៀមបញ្ជូនមន្ត្រីជាន់ខ្ពស់របស់អគ្គលេខាធិការដ្ឋាន អជបគញ ទៅចូលរួមជាអ្នកសង្កេតការណ៍នៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំ លើកទី២ ស្តីពីបណ្តាញកោសល្យវិច័យវិទ្យាសាស្ត្រអាស៊ាន នៅប្រទេសឥណ្ឌូនេស៊ី ( ថ្ងៃទី០១-០៣ ខែមិថុនាឆ្នាំ២០១០) ។

-ត្រៀមសហការជាមួយ UNODC រៀបចំការបណ្តុះបណ្តាលស្តីពីការប៉ាន់ប្រមាណភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់និងឧក្រិដ្ឋកម្មឆ្លងដែន នៅខេត្តស្វាយរៀង ថ្ងៃទី២៥ខែឧសភា និង នៅប៉ោយប៉ែត ខេត្តបន្ទាយមាន

ជ័យ ថ្ងៃទី២៧ខែឧសភាឆ្នាំ២០១០ ។

-ត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគី លើកទី១ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៃព្រះរាជាណាចក្រកម្ពុជា ជាមួយ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៃសាធារណរដ្ឋប្រជាមានិតចិន ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដែលនឹងព្រឹត្តទៅនៅថ្ងៃទី១៨ ឧសភា ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

-ត្រៀមចាត់មន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលចំនួន២វគ្គ ស្តីពីការអនុវត្តន៍ច្បាប់គ្រឿងញៀន និងការវិភាគគ្រឿងញៀន នៅសាធារណរដ្ឋកូរ៉េ ( ថ្ងៃទី០៩ឧសភា ដល់ ថ្ងៃទី៣០មិថុនា និង ថ្ងៃទី១០ឧសភា ដល់ ០៩កក្កដា ឆ្នាំ ២០១០) ។

***៥-នីតិកម្ម :***

-បន្តកិច្ចសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីជំរុញការកែសំរួលសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យចប់ជាស្ថាពរនៅចុងខែឧសភាឆ្នាំ២០១០ តាមអនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ។

ដើម្បីអនុវត្តបានសំរេចទិសដៅខាងលើ អគ្គលេខាធិការដ្ឋាន អជបគញ នឹងខិតខំជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងយកចិត្តទុកដាក់លើការងារសំខាន់ៗមួយចំនួនទៀត ជាអាទិ៍ ការត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការអនុវត្តន៍ គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងបន្តជំរុញការអនុវត្តន៍ផែនការប្រតិបត្តិគំរូ សំរាប់ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ដើម្បីធ្វើជាចំណុចដកពិសោធន៍ សំរាប់ពង្រីកកិច្ចសហប្រតិបត្តិការឱ្យមានប្រសិទ្ធភាពទៅកាន់រាជធានី-ខេត្តនានាទូទាំងប្រទេសនៅក្នុងឆមាសទី២ ឆ្នាំ២០១០នេះ ព្រមទាំងបន្តអនុវត្តតាមអនុសាសន៍ទាំង១២ចំណុច របស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

**<u>ចំលងជូន</u> :**

-ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**

**-ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អជបគញ**

**-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ**

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ